ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០២២ ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអញ្ជើញចូលរួមវេទិកាថ្នាក់រដ្ឋមន្ត្រីសម្រាប់កិច្ចសហប្រតិបត្តិការនៅឥណ្ឌូ-ប៉ាស៊ីហ្វិក បានចូលរួមថ្លែងបទអន្តរគមន៍ក្នុងកិច្ចប្រជុំតុមូល ស្តីពី «សន្តិសុខ និងការការពារជាតិនៅតំបន់ឥណ្ឌូប៉ាស៊ីហ្វិក» នៅទីក្រុងប៉ារីស ប្រទេសបារាំង ដែលរួមមានខ្លឹមសារដូចខាងក្រោម៖

«បន្ទាប់ពីបានថ្លែងអំណរគុណចំពោះលោកជំទាវ Florence Parly រដ្ឋមន្ត្រីការពារជាតិបារាំងដែលបានផ្តល់វេទិកាក្នុងការធ្វើបទអន្តរាគមន៍ស្តីពី «សន្តិសុខនិងការការពារជាតិនៅតំបន់ឥណ្ឌូប៉ាស៊ីហ្វិក» ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានលើកឡើងដូចតទៅ៖

ខ្ញុំសុំលើកឡើងនូវឧទាហរណ៍មួយនៃការប៉ះពាល់ដ៏គួរឱ្យសោកស្តាយ ដែលបណ្តាលមកពីការប្រកួតប្រជែងភូមិសាស្ត្រនយោបាយនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក និងសូមមិនលើកឡើងវិញដដែលៗនូវសារសំខាន់ខាងផ្នែកយុទ្ធសាស្ត្រ សន្តិសុខ សេដ្ឋកិច្ច ពាណិជ្ជកម្ម ប្រជាសាស្ត្រនៃតំបន់ឥណ្ឌូប៉ាស៊ីហ្វិកនេះទេ។

សមុទ្រចិនខាងត្បូង គឺពិតជាតំបន់មួយដែលមានសារសំខាន់ និងផលប្រយោជន៍ទាំងនេះលាយឡំគ្នាយ៉ាងជាក់ច្បាស់ និងប្រកបដោយគ្រោះថ្នាក់។ ប្រទេសដែលគួរជាអ្នកពាក់ព័ន្ធ គឺប្រទេសដែលកំពុងមានជម្លោះដណ្តើមនូវអធិបតេយ្យភាពនៅផ្នែកណានោះនៃតំបន់សមុទ្រនេះ ទោះបីទឡ្ហីករណ៍ខាងផ្នែកច្បាប់ និងប្រវត្តិសាស្ត្រ ដែលគេលើកឡើងដើម្បីធ្វើជាអំណះអំណាងនៃការទាមទាររបស់គេនោះយ៉ាងណាក៏ដោយ។

ប៉ុន្តែប្រទេសតូចដូចកម្ពុជា ក៏ត្រូវទទួលរងគ្រោះផងដែរ។ ដោយសារតែអ្វីទាំងអស់ដែលប្រទេសចិនធ្វើនៅក្នុងតំបន់នេះ ត្រូវបានសហរដ្ឋអាមេរិកតាមដាន និងវិភាគយ៉ាងល្អិតល្អន់នោះ សូម្បីតែកិច្ចសន្យារវាងកម្ពុជា និងចិន នៅក្នុងការស្តារជួសជុល និងការធ្វើទំនើបកម្មមូលដ្ឋានទ័ពជើងទឹករាមនេះ ក៏បានក្លាយជាចំណុចកណ្តាលនៃការចោទប្រកាន់ នៃការដាក់សម្ពាធរហូតដល់ការគំរាម



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

កំហែងផង។ ក្នុងខណៈដែលការងារជួសជុលមូលដ្ឋាននេះកំពុងដំណើរការនៅឡើយ គេបានចោទប្រកាន់យើងរួចទៅហើយថា បានផ្តល់ឱ្យប្រទេសចិននូវតំបន់ផ្តាច់មុខនៅក្នុងមូលដ្ឋាននេះ។

ខ្ញុំសូមជម្រាបជូនអង្គប្រជុំថា កម្ពុជាប្រកាន់នូវនយោបាយអព្យាក្រិត្យអចិន្ត្រៃយ៍។ រដ្ឋធម្មនុញ្ញកម្ពុជាមិនអនុញ្ញាតឱ្យមានវត្តមានយោធាបរទេសនៅលើទឹកដីរបស់ខ្លួននោះទេ ហើយក៏មិនអនុញ្ញាតឱ្យកម្ពុជាបញ្ជូនកងទ័ពរបស់ខ្លួនទៅក្រៅប្រទេសនោះដែរ លើកលែងតែក្រោមធ្វ័ត្ររបស់អង្គការសហប្រជាជាតិ ក្នុងនោះគឺបេសសកកម្មរក្សាសន្តិភាព។ រាម គឺជាមូលដ្ឋានជើងទឹកដ៏តូចមួយ ហ៊ុមព័ទ្ធទៅដោយសណ្ឋាគារ និងតំបន់ទេសចរណ៍។ មូលដ្ឋាននេះ គ្មានគោលដៅណាផ្សេងក្រៅពីការការពារដែនសមុទ្ររបស់យើង និងការពារអធិបតេយ្យ បូរណភាពទឹកដីរបស់យើង ដែលជាញឹកញាប់ត្រូវបានគេរំលោភបំពាន។ ក្នុងឋានៈជាប្រទេសអធិបតេយ្យ កម្ពុជាមានសិទ្ធគ្រប់យ៉ាងទាំងអស់នៅក្នុងការជ្រើសរើសមធ្យោបាយ ប្រកបដោយប្រសិទ្ធភាពបំផុតដើម្បីការពារប្រជាជាតិរបស់យើង ប៉ុន្តែយើង នឹងធ្វើការជ្រើសរើសមធ្យោបាយនោះដោយគោរពយ៉ាងម៉ឺងម៉ាត់បំផុតចំពោះរដ្ឋធម្មនុញ្ញរបស់យើង៕»

ថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០២២